# Living the Lotus 2

## Buddhism in Everyday Life

2025
VOL. 233




## The Inauguration Ceremony for Rissho Kosei-kai of San Antonio
## A New Beginning with Gratitude and Resolve

Living the Lotus
Vol. 233 (February 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# បណ្ដុះបណ្ដាលអនាគតកាល

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## តើនរណាជាអ្នកបង្កើតសង្គមគ្រោតគ្រាត

សូមអភ័យទោសដោយខ្ញុំព្រះករុណាអាត្មាភាពចាប់ផ្ដើមបើកឆាកដោយសុំសួរសំណួរមួយទៅកាន់អ្នកទាំងអស់គ្នា។

ឧបមាថានៅពីមុខយើងមានផ្លែក្រូចបី។ប្រសិនបើគេឱ្យយើងឱ្យក្រូចនោះទៅមនុស្សពីរនាក់ចែកគ្នាតើត្រូវចែកយ៉ាងម៉េច?

ខ្ញុំព្រះករុណាអាត្មាភាពបានឃើញក្នុងសៀវភៅមួយដែលមានសរសេរថាគ្រូបឋមម្នាក់ហុចក្រូចបីទៅសិស្សពីរនាក់ហើយសួរថា៖តើឯងទាំងពីរនឹងចែកគ្នាដូចម្ដេច?

ពេលនោះសិស្សម្នាក់ឆ្លើយថា៖បាទមួយយកទៅថ្វាយព្រះហើយសល់ពីរចែកគ្នាមួយម្នាក់។គ្រូគ្រវីក្បាលបដិសេធហើយនិយាយថា៖និយាយបានតែផ្ដាស។ក្រូចបីចែកគ្នាពីរនាក់បានក្រូចមួយនិងមួយកំណាត់ដឹងទេ?

ពិតហើយចម្លើយគ្រូត្រឹមត្រូវប្រសិនបើវាជាសំ ណួរគណិត ។នៅក្នុងកិច្ចសន្ទនាលើវេទិកានៃសាស្រ្ដាចារ្យហាណោកា ដៃហ្កាគឺជាអ្នកឯកទេសអក្សរសិល្ប៍កុមារជាមួយនឹងលោកយោស៊ីយោកា តាស្កឹដែលជាអ្នកស្រាវជ្រាវវប្បធម៌កុមារ អ្នកទាំងពីរបានលើកយករឿងនេះមកនិយាយ ហើយបានពិភាក្សាពីសារសំខាន់នៃការអប់រំកុមារតូចៗនិងមនោសញ្ចេតនាបែបសាសនាថាអវត្ត មាននៃការគោរពចំពោះអត្ថិភាពដែលខ្ពស់ជាងមនុស្សគឺជាមូលហេតុធំដែលធ្វើឱ្យបេះដូងលែងមានភាពរលោងម៉ត់ខៃគ្មានសន្ដោសហើយនិងធ្វើឱ្យសង្គមទៅជាគ្រោតគ្រាត។

ថ្មីៗនេះមានម្ដាយខ្លះតវ៉ាទៅសាលាដែលកូនរៀនថាខ្លួនបានបង់ថ្លៃបាយថ្ងៃត្រង់ហើយ កូនៗគ្មានកាតព្វកិច្ចនឹងលើកដៃសំពះថ្លែងអំណរគុណនរណាមុននឹងទទួលទានបាយនោះទេ។សេចក្ដីនេះមានសរសេរនៅក្នុងសៀវភៅរបស់សាស្រ្ដាចារ្យមូរ៉ាកាមី កាហ្ស៊ុអូដែលជាអ្នកឯកទេសនៃវិទ្យាសាស្ត្រហ្សែន។
ក៏ប៉ុន្ដែដូចដែលអ្នកទាំងអស់គ្នាធ្លាប់ដឹងហើយថាពាក្យថា “ខ្ញុំសូមទទួលទានអាហារនេះដោយអំណរគុណ” ដែលជនជាតិយើងតែងតែនិយាយដោយលើកដៃសំពះមុននឹងទទួលទានអាហារគឺមានន័យថា “យើងខ្ញុំសូមទទួលទានជីវិតអ្នក” ដើម្បីឱ្យយើងខ្ញុំរស់រានមានជីវិត។ (មូរ៉ាកាមី កាហ្ស៊ុអូ) គឺជាពាក្យសម្រាប់សម្ដែងនូវការដឹងគុណចំពោះ

ជីវិតដែលចិញ្ចឹមដោយមហាធម្មជាតិរួចហើយចំពោះព្រះឬទេវតានិងមនុស្សជាច្រើនដែលផ្តល់អា ហារទាំងនេះមកដល់យើង។ពោលគឺ “ទឹកចិត្តគោរព” ។

ឥរិយាបទដែលគិតតែពីរឿងខាតចំណេញឬភាពសមហេតុសមផលតែម្យ៉ាងហើយភ្លេចគិតពីទឹកចិត្តគោរពនេះនៃមាតាបិតានិងមនុស្សចាស់ទាំងឡាយជះឥទ្ធិពលធ្ងន់ធ្ងរទៅលើបេះដូងនៃកុមារនិងយុវជនដែលនឹងបន្តវេនវែកពុនសង្គមជាតិនៅថ្ងៃមុខដែលធ្វើឱ្យមានក្តីបារម្ភនោះប្រហែលជាមិនមែនមានតែខ្ញុំព្រះករុណាអាត្មាភាពតែម្នាក់ទេ។

## អនាគតកាលគឺនៅ “បច្ចុប្បន្ននេះនិងទីនេះ”

ក៏ប៉ុន្តែខ្ញុំព្រះករុណាអាត្មាភាពគិតឃើញបែបនេះ។នៅប្រទេសជប៉ុននៅពេលបុណ្យចូលឆ្នាំមនុស្សជាច្រើននាំគ្នាទៅសំពះព្រះឬទេវតាឬក៏ព្រះពុទ្ធនៅទីអារាមឬវត្តហើយនៅពេលបុណ្យបារមីដែលចិនគេហៅថាបុណ្យឆេងម៉េងគេនាំគ្នាទៅផ្នូរគោរពព្រលឹងបុព្វការីដែលស្លាប់ទៅហើយដែរ។នៅពេលបុណ្យផ្ជុំបិណ្ឌក៏គេធ្វើការគោរពដោយទទួលព្រលឹងដូនតាដែរ។ម្យ៉ាងទៀតនៅស្រុកជប៉ុននេះមានទំនៀមទម្លាប់ប្រពៃណីគោរពសាសនាស៊ីនតូផង ព្រះពុទ្ធសាសនាផង សាស នាខុងជឺផងព្រមទាំងទទួលឥទ្ធិពលពីទំនៀមទម្លាប់ប្រពៃណីបស្ចឹមប្រទេសផងដែរគឺថាយើងទាំងអស់គ្នាទទួលបាននិងរៀនសូត្រនូវការបង្រៀនប្រៀនប្រដៅបែបមនោសញ្ចេតនាជាច្រើនបែបហើយព្រមទាំងបានធ្វើឱ្យការបង្រៀនទាំងនោះរស់នៅប្រកបដោយភាពសុខដុំរមនាស្អិតស្អែរជាមួយគ្នា។

ខ្ញុំព្រះករុណាអាត្មាភាពគិតថាមិនមែនតែជប៉ុនមួយទេដែលមានការគោរពចំពោះវត្ថុថ្លៃថ្លានោះនៅប្រទេសណាក៏មានវប្បធម៌សាសនាដែរ។ពោលគឺថាមនុស្សទាំងឡាយនរណាម្នាក់ក៏មានបេះដូងគោរពនៅក្នុងខ្លួនដែរ។បើដូច្នេះមែនយើងត្រូវតែធ្វើឱ្យអ្នកដែលបានភ្លេចបេះដូងគោរពនោះចេះគោរពមកវិញហើយចង់ឱ្យកុមារមើលឃើញកិច្ចប្រតិបត្តិសេចក្តីគោរពចំពោះវត្ថុថ្លៃថ្លានៃមាតាបិតានោះនៅក្នុងជីវភាពពិតៗផងដែរ។ការសូត្រធម៌នៅមុខព្រះពុទ្ធរូបជារៀងរាល់ថ្ងៃក៏ជាឱកាសដ៏សំខាន់មួយដែរ។

ពីព្រោះថាចំណុចចាប់ផ្តើមនៃអនាគតកាលគឺបច្ចុប្បន្នកាល។យើងដុសខាត់បេះដូងយើងនៅពេលឥឡូវនេះ នៅទីនេះហើយខិតខំប្រតិបត្តិនូវអ្វីដែលអាចធ្វើបានគឺជាការបណ្តុះបណ្តាលបេះដូងកូនចៅយើងដែលជាអ្នកបន្តវេនវែកពុនអនា គតកាលហើយនិងជាការបណ្តុះបណ្តាលអនាគ តកាលដោយជឿទៅវិញទៅមកលើធាតុជាព្រះពុទ្ធដែលមនុស្សម្នាក់ៗមាន។បើនិយាយដោយទស្សនៈមួយទៀតគឺប្រសិនបើយើងម្នាក់ៗលូតលាស់ហើយឡើងល្អអនាគតកាលដ៏ភ្លឺត្រចះក៏នឹងកើតឡើង។

បើនិយាយពីការអប់រំកុមារតូចៗការគោរពថ្វាយបង្គំព្រះឬព្រះពុទ្ធជារៀងរាល់ថ្ងៃដែលធ្វើឱ្យគ្រួសារមានភាពកក់ក្តៅនិងសុខដុំរមនានោះហើយដែលជាការអប់រំដ៏ល្អជាងអ្វីទាំងអស់។ដូចលោកអ្នកឯកទេសខាងការអប់រំទារកនៅក្នុងផ្ទៃមាតានិយាយដែរថាកាលណាមាតាមានចិត្តស្ងប់ កក់ក្តៅទារកនៅក្នុងផ្ទៃក៏នឹងទទួលឥទ្ធិពលល្អពីនោះដែរហើយចំណងនិស្ស័យរវាងមាតានិងបុត្រក៏បានល្អប្រសើរ។



ដូចដែលបានរៀបរាប់មកនេះក្នុងន័យធ្វើឱ្យគ្រួសារមានភាពកក់ក្តៅនិងស្មេរភាពផងដែរយើងទាំងអស់គ្នាគួរតែគិតឱ្យដិតដល់ពីពាក្យទាំងបីឃ្លាថា “សូមអរគុណ” “ខ្ញុំសូមទទួលទានអាហារឆ្ងាញ់” “ខ្ញុំសូមអរគុណចំពោះអាហារដែលបានផ្តល់មកឱ្យ” ហើយជារៀងរាល់ថ្ងៃត្រូវប្រើពាក្យទាំងនេះឱ្យទៅជាទម្លាប់។ពីព្រោះថានៅពេលដែលឃើញមាតាបិតានិងមនុស្សចាស់ធ្វើបែបនេះបេះដូងកុមារនឹងទៅជារលោងរលើបមានទឹកដមហើយនឹងលូតលាស់។

『កូសេ』 លេខខែ២ឆ្នាំ២០២៥




# A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp